May 10, 2019

# អ្នករាយការណ៍ពិសេសអ.ស.បបន្តបង្ហាញក្តីបារម្ភចំពោះសេរីភាពនយោបាយនៅកម្ពុជា



លោកស្រី រ៉ូណា ស្មីត (Rhona Smith) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ថ្លែងទៅកាន់អ្នកសារព័ត៌មាននៅក្នុងសន្និសីទសារព័ត៌មានមួយ នៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៩។

**ហ៊ុល រស្មី | VOA Khmer, 09 ឧសភា 2019**

*ក៏ប៉ុន្តែដំណាលគ្នានឹងការបារម្ភនោះ លោកស្រី រ៉ូណា ស្មីត ក៏បានកត់សម្គាល់ឃើញមានការរីកចម្រើនជាវិជ្ជមានមួយចំនួនក្នុងបេសកកម្មរយៈពេល១១ថ្ងៃនៅកម្ពុជាលើកនេះ។*

*ភ្នំពេញ — លោកស្រី រ៉ូណា ស្មីត* (Rhona Smith) *អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា កត់សម្គាល់នៅថ្ងៃព្រហស្បតិ៍នេះថា មានការវិវត្តជាវិជ្ជមានមួយចំនួនទាក់ទិនបញ្ហាកំណែទម្រង់ក្នុងវិស័យច្បាប់ ដីធ្លី និងសេវាគាំពារសង្គម។ ប៉ុន្តែសិទ្ធិសេរីភាពជាមូលដ្ឋានក្នុងការជួបប្រជុំ និងសិទ្ធិពលរដ្ឋក្នុងវិស័យនយោបាយនៅក្នុងប្រទេសកម្ពុជានៅតែជាកង្វល់នៅឡើយ។*

*នៅក្នុងសន្និសីទកាសែតបិទបញ្ចប់ដំណើរទស្សនកិច្ចរយៈពេល១១ថ្ងៃនៅកម្ពុជា នៅថ្ងៃនេះ មន្ត្រីអង្គការសហប្រជាជាតិ*

ដដែលបានលើកឡើងថា លោកស្រីបានដឹងអំពីចំណាត់ការនានាដែលបានធ្វើដោយក្រុមនគរបាល ឬតុលាការប្រឆាំងនឹងអតីតសមាជិក និងមន្ត្រីជាប់ឆ្នោតរបស់អតីតគណបក្សសង្គ្រោះជាតិចំនួន៨០រូប នៅថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងដីកាកោះហៅចំនួន២៥ ដែលចេញដោយសាលាដំបូងខេត្តបាត់ដំបងនៅក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ។

លោកស្រី រ៉ូណា ស្មីត (Rhona Smith) បញ្ជាក់ថា៖ «ចំពោះទស្សនៈរបស់ខ្ញុំ ចំណាត់ការបែបនេះ មិនអាចនាំទៅរកការពង្រឹងសិទ្ធិនយោបាយ និងលំហប្រជាធិបតេយ្យ»។

ក្នុងសេចក្ដីថ្លែងការណ៍របស់ខ្លួន លោកស្រីរ៉ូណា ស្មីត បានលើកពីការជំទាស់របស់លោកស្រីទៅនឹងការបន្តឃុំខ្លួនលោក កឹម សុខា អតីតប្រធានអតីតគណបក្សសង្គ្រោះជាតិ ហើយលោកស្រីបានអំពាវនាវឲ្យមានការដោះលែងលោក កឹម សុខា ចេញពីការឃុំខ្លួន និងពន្លឿនការបិទការស៊ើបសួរ ឬទម្លាក់ការចោទប្រកាន់មកលើរូបគាត់។



លោកស្រីរ៉ូណា ស្មីត (Rhona Smith) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួល បន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ធ្វើសន្និសីទព័ត៌មានក្នុងទីក្រុងភ្នំពេញ កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៩។ (ហ៊ុល រស្មី/VOA)

លោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា ច្រានចោលការវាយតម្លៃរបស់អ្នកស្រីស្មីតដោយលោកយល់ថា លោកស្រីទំនងជាមិនពេញចិត្តនឹងសន្តិភាពនិងស្ថិរភាពនយោបាយនៅកម្ពុជា។

*អ្នកនាំពាក្យរូបនេះបញ្ជាក់ថា៖ «គាត់មិនឲ្យតម្លៃពីសន្តិភាព ហើយនិងស្ថិរភាពដែលកម្ពុជាទទួលបានមុនពេលបោះឆ្នោត នៅពេលបោះឆ្នោត រហូតដល់បច្ចុប្បន្នកាលនេះ គឺប្រជាពលរដ្ឋលោកសប្បាយចិត្តណាស់អាហ្នឹងមួយ»។*

*ទោះជាយ៉ាងណាលោក ស៊ឹង សែនករុណា អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក គាំទ្រការលើកឡើងរបស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ៖*

*«ការលើកឡើងរបស់លោកស្រី រ៉ូណា ស្មីត វាជារឿងមួយដែលត្រឹមត្រូវហើយ ព្រោះការមើលឃើញនេះ យើងឃើញ ហើយមានការចាត់វិធានការហ្នឹង ក្នុងដំណាក់កាលនៃវត្តមានលោកស្រី នៅក្នុងប្រទេសយើងហ្នឹងតែម្តង»។*

*នៅពេលបំពេញទស្សនកិច្ចលើកទីប្រាំពីរនៅប្រទេសកម្ពុជា ដើម្បីពិនិត្យ និងវាយតម្លៃអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នកស្រីស្មីតបានជួបពិភាក្សា ជាមួយរដ្ឋមន្ត្រីសំខាន់ៗមួយចំនួន រួមមានលោក អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស លោក ជា សុផារ៉ា រដ្ឋមន្ត្រីក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ និងលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។*

*នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចរបស់លោកស្រី លោកស្រី រ៉ូណា ស្មីត ក៏បានអំពាវនាវឲ្យទម្លាក់ការចោទប្រកាន់លើអតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរីទាំងពីរនាក់ ដែលត្រូវបានចោទពី «បទផ្តល់ព័ត៌មានដល់រដ្ឋបរទេស»។ អ្នកកាសែតទាំងពីររូបត្រូវបានតុលាការកម្ពុជាដោះលែងឲ្យបានស្ថិតនៅក្រៅឃុំបណ្តោះអាសន្នកាលពីខែសីហា ឆ្នាំ២០១៨។*

*ជាមួយគ្នានោះ លោកស្រី ស្មីត ក៏ជំរុញប្រជាជនកម្ពុជាឲ្យផ្លាស់ប្តូរវប្បធម៌នយោបាយទៅជាកិច្ចសន្ទនាមួយ ដែលផ្តោតទៅលើបញ្ហាជាជាងផ្តោតលើបុគ្គល ដែលជាវិធីមួយដែលឈានទៅមុខ និងបង្កើតមូលដ្ឋានរឹងមាំសម្រាប់សន្តិភាពយូរអង្វែង ការអភិវឌ្ឍប្រកបដោយចីរភាព និងសម្រេចបានសិទ្ធិមនុស្សទាំងអស់។*